August 30, 2019

# នីតិវិធីបន្តរបស់គណៈកម្មការអឺរ៉ុបលើការព្យួរអនុគ្រោះពន្ធ EBA



*អ្នកស្រី ហ្វេដេរីកា មូហ្គារីនី (Federica Mogherini) តំណាងជាន់ខ្ពស់នៃសហភាពអឺរ៉ុប ផ្នែកកិច្ចការបរទេស និង គោលនយោបាយសន្តិសុខ និង ជាអនុប្រធានស្នងការអឺរ៉ុប ជួបជាមួយលោក ហ៊ុន សែន (រូបឃើញតែខ្នង) នៅទីក្រុងប្រ៊ុចសែ្សល ប្រទេសប៊ែលហ្សិក កាលពីថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៨។*

ដោយ មួង ណារ៉េត

2019-08-29

នីតិវិធី ៦ ខែ ដំបូងក្នុងការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពសិទ្ធិមនុស្ស មុននឹងព្យួរប្រព័ន្ធអនុគ្រោះពន្ធ EBA របស់សហភាពអឺរ៉ុប បានបិទបញ្ចប់ទៅហើយ កាលពីថ្ងៃទី១២ ខែសីហា។ ឥឡូវនេះ គណៈកម្មការអឺរ៉ុប កំពុងចាប់ផ្តើមនីតិវិធីបីខែបន្ទាប់ ដែលអាចឈានទៅព្យួរការអនុគ្រោះពន្ធ EBA ពីកម្ពុជា បើស្ថានភាពសិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពក្នុងវិស័យការងារ នៅតែមិនប្រសើរ។

តើនីតិវិធីបន្តរបស់គណៈកម្មការអឺរ៉ុប នៅមានអ្វីខ្លះទៀត?

មូលហេតុដែលនាំឱ្យសហភាពអឺរ៉ុប ចាប់ផ្តើមនីតិវិធី ដែលឈានទៅដល់ការព្យួរការអនុគ្រោះពន្ធ EBA ពីកម្ពុជា គឺដោយសារតែសហភាពអឺរ៉ុបមិនពេញចិត្ត ទៅនឹងចំណាត់ការរបស់របបលោក ហ៊ុន សែន ដែលរំលោភសិទ្ធិមនុស្ស បំផ្លាញប្រជាធិបតេយ្យធ្ងន់ធ្ងរ និង រឹតត្បិតសិទ្ធិសេរីភាពសហជីព កម្មករ និងសិទ្ធិដីធ្លីជាដើម ក្រោយរបបនេះ បានចាប់ប្រធានគណបក្សសង្គ្រោះជាតិលោក កឹម សុខា ដាក់ពន្ធនាគារ រម្លាយគណបក្សសង្គ្រោះជាតិ បណ្តេញអង្គការសង្គមស៊ីវិល បិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ធ្វើទុក្ខបុកម្នេញមន្ត្រីសហជីពកម្មករ បិទសិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងការតវ៉ាដោយសន្តិវិធី រៀបចំការបោះឆ្នោត ដោយផាត់ចោលគណបក្សប្រឆាំង ដែលមានអ្នកបោះឆ្នោតគាំទ្រជិតពាក់កណ្តាលប្រទេស និងបន្តធ្វើទុក្ខបុកម្នេញមន្ត្រីបក្សប្រឆាំងនៅមូលដ្ឋានជាដើម។

ប្រទេសកម្ពុជា ទទួលបានកម្មវិធីអនុគ្រោះពន្ធលើ«ទំនិញគ្រប់មុខ លើកលែងតែគ្រឿងសព្វាវុធ» (Everything But Arms) ឬហៅកាត់ថា EBA នេះ ដោយសារតែវាជាផ្នែកមួយ នៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ របស់សហភាពអឺរ៉ុប ដែលផ្ដល់ឱ្យតែប្រទេសក្រីក្រប៉ុណ្ណោះ។ គោលបំណងនៃការអនុគ្រោះពន្ធនេះ គឺចង់ឱ្យប្រទេសក្រីក្រទាំងនោះ មានឱកាសកាត់បន្ថយភាពក្រីក្រ តាមរយៈការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច ប្រកបដោយចិរភាព។

ទោះជាយ៉ាងនេះក្ដី ការផ្ដល់ការអនុគ្រោះពន្ធនេះ គឺមានភ្ជាប់លក្ខខណ្ឌធំៗមួយចំនួន ដែលប្រទេសនីមួយៗ ត្រូវបំពេញឱ្យបានជាដាច់ខាត។ លក្ខខណ្ឌទាំងនោះ រួមមានការគោរពសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ និង ការគោរពសិទ្ធិការងារ ដែលមានចែង នៅក្នុងគោលការណ៍ជាមូលដ្ឋាន នៃអនុសញ្ញាទាំងឡាយ ស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិការងាររបស់អង្គការសហប្រជាជាតិ និង អង្គការអន្តរជាតិខាងការងារ។

សហភាពអឺរ៉ុប បានថ្កោលទោស និងព្រមានរបបលោក ហ៊ុន សែន ជាច្រើនលើកច្រើនសាទៅហើយ ឱ្យស្ដារសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យឡើងវិញ បើចង់បន្តរក្សាប្រព័ន្ធការអនុគ្រោះពន្ធតទៅទៀត។ ប៉ុន្តែ របបលោក ហ៊ុន សែន នៅតែចចេសមិនព្រមស្ដារស្ថានការណ៍នេះឡើងវិញ ដោយរបបនេះសម្អាងថា ខ្លួនមិនបានធ្វើអ្វីខុសនោះឡើយ។ មិនតែប៉ុណ្ណោះមេដឹកនាំរបបនេះ គឺលោក ហ៊ុន សែន ថែមទាំងឌឺថា បើទោះបីជាអត់ EBA ក៏កម្ពុជាអត់បញ្ហា។ លោកថែមទាំងជំរុញឱ្យគេប្រញាប់ផ្ដាច់វាទៀតផង៖ *«បើសិនគេផ្ដល់ភាពអនុគ្រោះឱ្យយើង យើងក៏មិនអាចក្លាយទៅជាអ្នកមានបានទេ។ តែបើគេដកភាពអនុគ្រោះពីយើង ក៏មិនធ្វើឱ្យយើងស្លាប់ដែរ។ យល់ទេអាកន្លែងហ្នឹង? កុំធ្វើជាសត្វឆ្កែ គ្រាន់តែដើម្បីជាមួយនឹងឆ្អឹងឬសាច់មួយដុំ វាមិនថ្លៃថ្នូរទេ។ ឧទាហរណ៍គេគំរាម បើមិនធ្វើតាមអញ អញនឹងកាត់ផ្ដាច់នេះ កាត់ផ្ដាច់នោះ។ កាត់ទៅ ! លោកឯងកាត់ទៅ! ធ្វើឱ្យវាអស់សេចក្ដីទៅ»*។

ក្រោយការទុកឱកាសជាច្រើនលើក និង ភាពគ្មានប្រសើរឡើងផ្នែកសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ សហភាពអឺរ៉ុបបានសម្រេចដាក់ចេញជាផ្លូវការនូវនីតិវិធី ដែលឈានដល់ការព្យួរអនុគ្រោះពន្ធ EBA ពីកម្ពុជានេះ។

នីតិវិធីព្យួរការអនុគ្រោះពន្ធនេះ ចែកចេញជាបីដំណាក់កាលធំៗ៖

- ដំណាក់កាលទីមួយ គឺត្រួតពិនិត្យតាមដាន និង វាយតម្លៃស៊ីជម្រៅ ថាតើកម្ពុជាបានធ្វើអ្វីខ្លះ ដើម្បីកែប្រែស្ថានការណ៍បច្ចុប្បន្ន ដែលសហភាពអឺរ៉ុបស្នើឱ្យកែប្រែឬនៅ។ សហភាពអឺរ៉ុប ផ្ដល់ឱកាសឱ្យកម្ពុជា ក្នុងការចរចា និង ចូលរួមសហការ ក្នុងការប្រមូលព័ត៌មានចាំបាច់។ ដំណាក់កាលទីមួយនេះ មានរយៈពេល ៦ ខែ ដោយគិតចាប់ពី ថ្ងៃទី១២ ខែ កុម្ភៈ ដល់ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។ ដំណាក់កាល ៦ ខែ ដំបូងនេះ បានបិទបញ្ចប់ជាស្ថាពរទៅហើយ កាលពីថ្ងៃទី១២ ខែសីហា កន្លងទៅ។

ក្នុងដំណាក់កាលនោះ គណៈកម្មការអឺរ៉ុប ត្រូវជួបពិភាក្សាផ្ទាល់ជាមួយមន្ត្រីពាក់ព័ន្ធនានា រួមទាំងមន្ត្រីរដ្ឋាភិបាលកម្ពុជា និង មន្ត្រីសហជីពកម្មករ និង មន្ត្រីអង្គការសង្គមស៊ីវិល រួមទាំងតំណាងខាងថៅកែរោងចក្រកាត់ដេរផង។

គណៈប្រតិភូស្វែងរកការពិតរបស់គណៈកម្មការអឺរ៉ុប បានបំពេញទស្សនកិច្ចចំនួនពីរលើក ក្នុងរយៈពេលនេះ។ ភាគីដែលពាក់ព័ន្ធ ផ្សេងៗ អាចដាក់ឯកសារភស្តុតាង ទៅគណៈកម្មការអឺរ៉ុប។ ឯកសារទាំងនេះ អាចជាកង្វល់អំពីផលប៉ះពាល់ ករណីព្យួរប្រព័ន្ធអនុគ្រោះពន្ធ EBA និង ជំហរការពារចំណាត់ការ ដែលរងការរិះគន់ ថារំលោភសិទ្ធិមនុស្ស និង បំផ្លាញប្រជាធិបតេយ្យ។

ខាងសមាគមថៅកែរោងចក្រនៅកម្ពុជា (GMAC) បានដាក់ឯកសារទៅគណៈកម្មការអឺរ៉ុបដែរ ដោយបង្ហាញអំពីភាពប្រសើរឡើង និងការគោរពសិទ្ធិការងារ និងសិទ្ធិសហជីពរបស់សមាគមរោងចក្រកាត់ដេរ ដែលសហភាពអឺរ៉ុបគួរពិចារណា មុននឹងព្យួរការអនុគ្រោះពន្ធពីកម្ពុជា។ ជាមួយគ្នាដែរ សមាគមថៅកែរោងចក្រនៅកម្ពុជា ថ្លែងពីក្ដីកង្វល់ ថា ការអនុគ្រោះពន្ធ EBA នេះ មានផលប៉ះពាល់ដល់ប្រជាពលរដ្ឋខ្មែរប្រមាណ ៣លាននាក់ បើសហភាពអឺរ៉ុបសម្រេចព្យួរមែននោះ។ គ្រាន់តែវិស័យរោងចក្រកាត់ដេរ គឺផ្ដល់ការងារដល់កម្មករ ៧៥០,០០០ នាក់ ដែលស្មើនឹងជាងពាក់កណ្ដាល នៃកម្លាំងពលកម្មសរុបនៅកម្ពុជា។

ខាងរបបលោក ហ៊ុន សែន ក៏បានដាក់ឯកសាររបស់ខ្លួន ជូនទៅគណៈកម្មការអឺរ៉ុបដែរ គឺដាក់នៅកៀកថ្ងៃបិទបញ្ចប់ នៃដំណាក់កាល ៦ ខែដំបូងនោះ។ នេះបើតាមមន្ត្រីនាំពាក្យគណៈកម្មការអឺរ៉ុបផ្នែកពាណិជ្ជកម្ម និង កសិកម្ម លោក ដានីញ៉ែល រ៉ូសារីយ៉ូ (Daniel Rosario) ដែលប្រាប់អាស៊ីសេរី តាមសារអេឡិចត្រូនិក ភ្លាមៗក្រោយបិទបញ្ចប់នីតិវិធី ៦ ខែដំបូងកាលពីថ្ងៃទី១៣ ខែសីហានោះ។

•ដំណាក់កាលទីពីរ មានរយៈពេល ៦ ខែដែរ ប៉ុន្តែចែកចេញជាបី ដំណាក់កាលតទៅទៀត (គឺដំណាក់កាល ៣ ខែ ដំណាក់កាល ១ ខែ និង ដំណាក់កាល ២ ខែ)៖

○ដំណាក់កាល ៣ ខែដំបូង គឺជាពេលសរសេររបាយការណ៍សន្និដ្ឋានបឋម ដោយផ្អែកលើអ្វីដែលប្រតិភូគណៈកម្មការអឺរ៉ុប ប្រមូលបានក្នុងអំឡុងទស្សនកិច្ចស្វែងរកការពិតនៅកម្ពុជា និង ឯកសារភស្តុតាង ដែលប្រមូលបានពីភាគីពាក់ព័ន្ធ។ ដំណាក់កាលបីខែដំបូងនេះ បានចាប់ផ្ដើមតាំងពីថ្ងៃទី ១៣ ខែ សីហា មកម្ល៉េះ ពោលគឺចាប់ផ្ដើមភ្លាមៗ ក្រោយចប់ដំណាក់កាល ៦ ខែ ដំបូង។ ដំណាក់កាលសរសេររបាយការណ៍បឋមនេះ នឹងបិទបញ្ចប់នៅថ្ងៃទី១២ ខែវិច្ឆិកា។

ដំណាក់កាល ១ខែបន្ទាប់ គឺចាប់ផ្ដើមភ្លាមៗ ក្រោយសរសេររបាយការណ៍សន្និដ្ឋាននោះចប់។ ដំណាក់កាលនេះ គឺគិតចាប់ពី ថ្ងៃទី១៣ ខែ វិច្ឆិកា ដល់ថ្ងៃទី ១២ ខែ ធ្នូ។ ក្នុងរយៈពេលពេញមួយខែនេះ គណៈកម្មការអឺរ៉ុប ទុកឱកាសឱ្យរបបលោក ហ៊ុន សែន ឆ្លើយតប។ ផុតពីមួយខែនេះទៅ គឺចូលដល់ដំណាក់កាល ២ ខែចុងក្រោយ។

ដំណាក់កាល ២ ខែចុងក្រោយនេះ គឺជាពេលសរសេរសេចក្ដីសម្រេចស្ថាពរ ថាតើត្រូវព្យួរ ឬ មិនត្រូវព្យួរការអនុគ្រោះពន្ធ EBA នោះ។

មន្ត្រីនាំពាក្យគណៈកម្មការអឺរ៉ុបផ្នែកពាណិជ្ជកម្ម និង កសិកម្ម លោក ដានីញ៉េល រ៉ូសារីយ៉ូ ប្រាប់អាស៊ីសេរី តាមសារអេឡិចត្រូនិក កាលពីថ្ងៃទី ១៣ ខែ សីហា ថា សេចក្ដីសម្រេចស្ថាពរ នឹងត្រូវចុះផ្សាយក្នុងទិនានុប្បវត្តិ (ទស្សនាវដ្ដី) ផ្លូវការរបស់គណៈកម្មការអឺរ៉ុប នៅអំឡុងពាក់កណ្ដាលខែ កុម្ភៈ ឆ្នាំ២០២០ ខាងមុខ។

• ដំណាក់កាលទី ៣ គឺជាពេលកំណត់ ដែលត្រូវអនុវត្តការព្យួរប្រព័ន្ធអនុគ្រោះពន្ធនោះ ដោយត្រូវរាប់ ៦ ខែ ចាប់ពីក្រោយសេចក្ដីសម្រេចស្ថាពរនោះ។ បើគណៈកម្មការនេះ សម្រេចដកការអនុគ្រោះពន្ធពីកម្ពុជា នៅអំឡុងពាក់កណ្ដាលខែ កុម្ភៈ ឆ្នាំ ២០២០ មែននោះ ការអនុវត្តការព្យួរប្រព័ន្ធអនុគ្រោះពន្ធនេះពិតប្រាកដ នឹងចូលជាធរមាននៅ ៦ខែបន្ទាប់មកទៀត។ មានន័យថា ការព្យួរការអនុគ្រោះពន្ធ EBA នឹងចាប់ផ្ដើមអនុវត្ត នៅពាក់កណ្ដាលខែសីហា ឆ្នាំ២០២០។

សហភាពអឺរ៉ុប ចាត់ទុកចំណាត់ការរបស់របបលោក ហ៊ុន សែន ក្នុងរយៈពេលជិតពីរឆ្នាំចុងក្រោយនេះ ថាជាអំពើរំលោភសិទ្ធិមនុស្ស និង បំផ្លាញប្រជាធិបតេយ្យធ្ងន់ធ្ងរ ដែលផ្ទុយទៅនឹងលក្ខខណ្ឌ ដែលកម្ពុជាត្រូវតែគោរព ដើម្បីជាថ្នូរនឹងការបន្តទទួលបានប្រព័ន្ធអនុគ្រោះពន្ធនេះ។ សហភាពអឺរ៉ុប ក៏បានទុកឱកាសឱ្យរបបនេះ ស្ដារស្ថានភាពនេះឡើងវិញដែរ។ ប៉ុន្តែ មន្ត្រីជាន់ខ្ពស់សហភាពអឺរ៉ុប នៅតែហួសចិត្ត ដែលរបបលោក ហ៊ុន សែន មិនព្រមធ្វើតាមសំណូមពររបស់សហភាពអឺរ៉ុប ឱ្យស្ដារស្ថានភាពនេះឡើងវិញ។

ស្នងការពាណិជ្ជកម្មសហភាពអឺរ៉ុប អ្នកស្រី សេស៊ីល្យា ម៉ាមស្ត្រុម (Cecilia Malmstrom) ប្រាប់អាស៊ីសេរី កាលពីដើមខែ មិថុនា ដោយសម្ដែងការខកចិត្ត ដែលអ្វីៗកំពុងស្ថិតក្នុងដៃលោក ហ៊ុន សែន ប៉ុន្តែ លោកបែរជាមិនស្ដារស្ថានភាពអាក្រក់នេះសោះ៖ «*ចាស៎! រឿងនេះ គឺស្ថិតក្នុងកណ្ដាប់ដៃទាំងស្រុងរបស់លោក ហ៊ុន សែន និងរដ្ឋបាលរបស់លោក។ ពីព្រោះថា យើងគិតថា ស្ថានភាពបានដើរថយក្រោយ ជុំវិញរឿងសិទ្ធិមនុស្សនារយៈពេលចុងក្រោយនេះ... រឿងដែលគណបក្សប្រឆាំងត្រូវបានគេរំលាយ ការបោះឆ្នោតមិនត្រូវបានទទួលស្គាល់ដោយប្រទេសជាច្រើននៅលើពិភពលោក...។ យើងឃើញមានការកម្រិតលំហ សង្គមស៊ីវិល និងប្រព័ន្ធសារព័ត៌មានជាដើម។ ក៏មានក្ដីបារម្ភមួយចំនួន អំពីបទដ្ឋានការងារ អំពើប្លន់យកដីធ្លីជាដើម។ យើងគិតថា មានការកែលម្អតិចតួចដែរ ខាងវិស័យសង្គមកិច្ច ដែលជារឿងល្អ ប៉ុន្តែយើងសង្ឃឹមថា មានការកែលម្អច្រើនជាងនេះ។ អ្វីៗគឺអាចកើតមានឡើងបាន។ ប៉ុន្តែ ក្នុងកណ្ដាប់ដៃលោក ហ៊ុន សែន ទំនងដូចជាមិនអាចកើតឡើងបានច្រើននោះទេ*»។

មិនមែនតែសមាគមរោងចក្រកាត់ដេរទេ ដែលភ័យខ្លាចបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធនេះ សូម្បីតែសហព័ន្ធស្រូវអង្ករកម្ពុជាឯណោះ ក៏ព្រួយបារម្ភយ៉ាងខ្លាំងណាស់ដែរ បើសហភាពអឺរ៉ុបដកប្រព័ន្ធនេះមែន ព្រោះការបាត់បង់ EBA នឹងធ្វើឱ្យឧស្សាហកម្មស្រូវអង្ករ ត្រូវបំផ្លាញខ្ទេចខ្ទី និងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាកសិករ ខ្មែរជាងកន្លះលានគ្រួសារ ដែលស្មើនឹងរាប់លាននាក់។ ស្ថាប័នធំៗទាំងនេះ បានអំពាវនាវសុំកុំឱ្យសហភាពអឺរ៉ុបព្យួរការអនុគ្រោះពន្ធនេះឱ្យសោះ។ ប៉ុន្តែ ការអំពាវនាវទៅសហភាពអឺរ៉ុប ដែលមិនមែនជាអ្នកធ្វើឱ្យស្ថានការណ៍អាក្រក់ដូចបច្ចុប្បន្ននេះ រងការរិះគន់ជុំទិសដែរ ថា អេះមិនចំរមាស់។

ប្រធានសហភាពសហជីពកម្មករ ប្រធានសម្ព័ន្ធសហគមន៍កសិករកម្ពុជា និងអ្នកវិភាគផង សុទ្ធតែយល់ថា ទាំងសមាគមរោងចក្រកាត់ដេរ និងសហព័ន្ធស្រូវអង្ករកម្ពុជា គួរតែយកពេលវេលានេះ ទៅជជែកជាមួយរបបក្រុងភ្នំពេញ ឱ្យស្ដារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស

ឡើងវិញ ប្រសើរជាងលើកកង្វល់ទៅសហភាពអឺរ៉ុប ព្រោះរបបលោក ហ៊ុន សែន ឯណោះទៅវិញទេ ដែលត្រូវទទួលខុសត្រូវចំពោះការណ៍ដែលធ្វើឱ្យប្រទេសកម្ពុជា ធ្លាក់ដល់កម្រិតបែបនេះ។

តំណាងជាន់ខ្ពស់ទទួលបន្ទុកកិច្ចការបរទេស និងគោលនយោបាយសន្តិសុខ និងជាអនុប្រធានស្នងការអឺរ៉ុប អ្នកស្រី ហ្វេដេរីកា ម៉ូហ្គេរីនី (Federica Mogherini) បញ្ជាក់ប្រាប់សារព័ត៌មានជប៉ុន នៅចុងខែកក្កដាកន្លងទៅនេះ ថាជំហររបស់សហភាពអឺរ៉ុប គឺនៅតែដដែល គឺស្ថានភាពរំលោភសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យនៅតែមិនប្រសើរ។ ទោះជាយ៉ាងនេះក្តី អ្នកស្រីថា បង្ហើបថា របបលោក ហ៊ុន សែន នៅមិនទាន់យឺតពេលនៅឡើយទេ បើប្រញាប់ស្តារសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យឡើងវិញនៅពេលនេះ បើចង់បញ្ជៀសការព្យួរអនុគ្រោះពន្ធនេះ៕